**ស្ថានទូតអូស្ត្រាលី**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

*ថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០២៦*

## ដំណើរទស្សនកិច្ចរបស់រដ្ឋមន្ត្រីអូស្ត្រាលីទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍អន្តរជាតិ បញ្ជាក់ជាថ្មីនូវភាពជាដៃគូដ៏យូរអង្វែងជាមួយកម្ពុជា

លោកជំទាវបណ្ឌិត Anne Aly សមាជិកសភា និងជារដ្ឋមន្ត្រីអូស្ត្រាលីទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍អន្តរជាតិ បានអញ្ជើញបំពេញទស្សនកិច្ចនៅកម្ពុជា នៅថ្ងៃទី៣០-៣១ ខែកក្កដា ដើម្បីពង្រឹងភាពជាដៃគូដ៏រឹងមាំ និងយូរអង្វែងរវាងប្រទេសទាំងពីរ។ ក្នុងអំឡុងពេលទស្សនកិច្ចនេះ លោកជំទាវរដ្ឋមន្ត្រី បានជួបពិភាក្សាការងារជាមួយ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់អូស្ត្រាលីចំពោះកម្ពុជា ក្នុងនាមជាដៃគូអភិវឌ្ឍន៍ដ៏រឹងមាំ និងគួរឱ្យទុកចិត្ត។

លោកជំទាវបណ្ឌិត Aly បានប្រកាសផ្តល់ថវិកាបន្ថែមចំនួន ៣ លានដុល្លារអូស្ត្រាលី ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាបន្តពង្រឹងប្រព័ន្ធគាំពារសង្គម ក្នុងគោលដៅជួយជ្រោមជ្រែងដល់គ្រួសារងាយរងគ្រោះដែលកំពុងប្រឈមនឹងវិបត្តិសេដ្ឋកិច្ច។ លើសពីនេះ លោកជំទាវក៏បានបញ្ជាក់ផងដែរថា ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) របស់អូស្ត្រាលីមកកាន់កម្ពុជា សម្រាប់ឆ្នាំ២០២៦-២០២៧ នឹងមានថវិកាប្រមាណ ៩៤,៤ លានដុល្លារអូស្ត្រាលី។

ទន្ទឹមនឹងនេះ លោកជំទាវបណ្ឌិត Aly បានអញ្ជើញទៅទស្សនកិច្ចនៅក្រុមហ៊ុនចំណីអាហារ គីរីរម្យ ហ្វ៊ូដ ប្រដាក់សិន ដែលទីនោះគឺជាកន្លែងដែលអូស្ត្រាលីកំពុងជួយដល់អាជីវកម្មក្នុងស្រុកឱ្យមានលទ្ធភាពឈានជើងចូលទៅកាន់ទីផ្សារអន្តរជាតិ បង្កើតឱកាសការងារសម្រាប់ស្ត្រី គាំទ្រដល់ជីវភាពរស់នៅរបស់ប្រជាជននៅតាមទីជនបទ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។ នៅក្នុងឱកាសអញ្ជើញ

ទៅពិនិត្យមើលជណ្តើរត្រីក្នុងខេត្តកំពង់ស្ពឺ លោកជំទាវបណ្ឌិត Aly ក៏បានប្រកាសផ្តល់ថវិកាចំនួន ៩ លានដុល្លារអូស្ត្រាលីបន្ថែមទៀត សម្រាប់ដំណាក់កាលថ្មីនៃកម្មវិធីបច្ចេកវិទ្យាជណ្តើរត្រី (FishTech) របស់មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ដើម្បីគាំទ្រដល់ភាពធន់នៃសេដ្ឋកិច្ចក្នុងតំបន់ សន្តិសុខស្បៀង និងចីរភាពនៃប្រព័ន្ធអេកូឡូស៊ីរបស់បរិស្ថាន។

ក្នុងអំឡុងពេលទស្សនកិច្ចនេះផងដែរ លោកជំទាវបណ្ឌិត Aly ក៏បានជួបសំណេះសំណាលជាមួយអតីតនិស្សិតអាហារូបករណ៍អូស្ត្រាលី (Australia Awards alumni) និងអ្នកស្ម័គ្រចិត្តអូស្ត្រាលី ដែលនេះបានបញ្ជាក់សារជាថ្មីពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងប្រទេសអូស្ត្រាលី និងកម្ពុជា និងការប្តេជ្ញាចិត្តរបស់យើងក្នុងការគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស។

ថ្លែងនាចុងបញ្ចប់នៃដំណើរទស្សនកិច្ចនេះ លោកជំទាវបណ្ឌិត Aly បានមានប្រសាសន៍ថា ភាពជាដៃគូទ្វេភាគីដ៏រឹងមាំបាននិងកំពុងបន្តនាំមកនូវផលប្រយោជន៍ជាក់ស្តែងសម្រាប់សហគមន៍នានានៅទូទាំងប្រទេសកម្ពុជា។

«អូស្ត្រាលីមានមោទនភាពក្នុងការឈរប្រកៀកស្មាជាមួយកម្ពុជា ក្នុងនាមជាដៃគូដ៏គួរឱ្យទុកចិត្ត និងមានទំនាក់ទំនងយូរអង្វែង។ តាមរយៈការគាំទ្រផ្នែកអភិវឌ្ឍន៍របស់យើង រួមទាំងការប្រកាសផ្តល់ជំនួយនានាដែលខ្ញុំបានធ្វើឡើងក្នុងអំឡុងពេលបំពេញទស្សនកិច្ចនេះ យើងកំពុងរួមចំណែកជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់នៅក្នុងប្រទេសកម្ពុជា។»

«អូស្ត្រាលីប្តេជ្ញាចិត្តធានាថា ភាពជាដៃគូរបស់យើងនៅក្នុងប្រទេសកម្ពុជា បន្តឆ្លើយតប និងស្របទៅនឹងអាទិភាព និងគោលដៅរបស់កម្ពុជា។»

អូស្ត្រាលីនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយកម្ពុជា ដើម្បីសម្រេចបាននូវលទ្ធផលជាក់ស្តែងនានា ដែលជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងគាំទ្រដល់តំបន់មួយដែលមានសន្តិភាព ស្ថិរភាព និងវិបុលភាព។

**ទំនាក់ទំនងព័ត៌មាន :** Media.Cambodia@dfat.gov.au